ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខ: [illegible] គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦

**គោរពជូន**

**ឯកឧត្តមអភិបាលខេត្តពោធិ៍សាត់**

**កម្មវត្ថុ** ៖ ករណីការអនុវត្តគម្រោងផ្លូវកៅស៊ូរបស់មន្ទីរសាធារណៈការនិងដឹកជញ្ជូនខេត្តត្រួតស៊ីគ្នាលើគម្រោងផ្លូវក្រាលក្រួសក្រហមប្រវែង២.៥៧០ម៉ែត្រ ឆ្នាំ២០១៤ របស់ឃុំអន្លង់វិល ស្រុកកណ្តៀង។

**យោង** ៖ - លិខិតលេខ១០៣៣/១៦ រប/ខពស ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៦អំពីរបាយការណ៍ស្តីពីការអនុវត្តគម្រោងត្រួតស៊ីគ្នាផ្លូវកៅស៊ូរបស់មន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តលើគម្រោងផ្លូវក្រាលក្រួសក្រហមប្រវែង២.៥៧០ម៉ែត្រ ឆ្នាំ២០១៤ ឃុំអន្លង់វិល ស្រុកកណ្តៀង។

- ចំណាររបស់អនុប្រធានប្រតិបត្តិនៃលេខាធិការដ្ឋាន គ.ជ.អ.ប. ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦ ឱ្យចុះត្រួតពិនិត្យ និងពិភាក្សាអំពីករណីគម្រោងត្រួតស៊ីគ្នាខាងលើ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមមេត្តាជ្រាបថា កាលពីថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៦ មន្ត្រីលេខាធិការដ្ឋាន គ.ជ.អ.ប. បានចុះត្រួតពិនិត្យ និងពិភាក្សាជាមួយមន្ត្រីពាក់ព័ន្ធនៃរដ្ឋបាលខេត្តពោធិ៍សាត់ មន្ទីរសាធារណៈការនិងដឹកជញ្ជូនខេត្ត និងក្រុមប្រឹក្សាឃុំអន្លង់វិល ស្រុកកណ្តៀង ក៏ដូចជាការចុះត្រួតពិនិត្យផ្ទាល់នៅទីតាំងគម្រោងផ្លូវកៅស៊ូប្រវែង១.៦០០ម៉ែត្ររបស់មន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តដែលកំពុងសាងសង់(បានបញ្ចប់ដំណាក់កាលក្រាលក្រួសក្រហម) ត្រួតស៊ីគ្នា និងគ្របលើមួយផ្នែកធំនៃផ្លូវក្រួសក្រហមប្រវែង២.៥៧០ម៉ែត្ររបស់ឃុំអន្លង់វិលដែលបានសាងសង់កាលពីឆ្នាំ២០១៤។ លទ្ធផលនៃការប្រជុំពិភាក្សាជាមួយអ្នកពាក់ព័ន្ធ ការពិនិត្យឯកសារគម្រោងក្រាលគ្រួសក្រហមរបស់ឃុំអន្លង់វិលឆ្នាំ២០១៤ និងការចុះត្រួតពិនិត្យផ្ទាល់នៅទីតាំង គម្រោងបង្ហាញថា គម្រោងកៅស៊ូរបស់មន្ទីរសាធារណៈការនិងដឹកជញ្ជូនខេត្តពិតជាកំពុងសាងសង់ត្រួតស៊ីគ្នា លើផ្លូវក្រួសក្រហមដែលមានស្រាប់របស់ឃុំអន្លង់វិល ទីតាំងគម្រោងនៅតាមមាត់ស្ទឹងពោធិ៍សាត់ក្នុងភូមិក្បាលរមាសដែលបានសាងសង់កាលពីឆ្នាំ២០១៤ ហើយការសាងសង់នេះមន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តបានជូនដំណឹងត្រឹមត្រូវជាផ្លូវការដល់ក្រុមប្រឹក្សាឃុំអន្លង់វិល (លិខិតលេខ១៧៨ សកពស ចុះថ្ងៃទី២៩ កុម្ភៈ ឆ្នាំ២០១៦) និងមានការឯកភាពក្នុងការទទួលយកគម្រោងនេះរបស់ក្រុមប្រឹក្សាឃុំអន្លង់វិល (យោងកំណត់ ហេតុកិច្ចរបស់ឃុំអន្លង់វិលចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៦ និងកិច្ចប្រជុំរបស់មន្ត្រីលេខាធិការដ្ឋាន គ.ជ.អ.ប. ជាមួយក្រុមប្រឹក្សាឃុំអន្លង់វិលនៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៦)។ ជាមួយគ្នានេះដែរ តាមរយៈកិច្ចប្រជុំពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ និងការចុះត្រួតពិនិត្យផ្ទាល់នៅទីតាំងគម្រោងក៏បានបង្ហាញច្បាស់ថា ក្រុមប្រឹក្សាឃុំអន្លង់វិល ពិសេសមេភូមិក្បាលរមាស និងប្រជាពលរដ្ឋដែលកំពុងរស់នៅតាមដងផ្លូវគម្រោងក្នុងភូមិក្បាលរមាសមានការពេញចិត្តជាខ្លាំងជាមួយនឹងគម្រោងកៅស៊ូរបស់មន្ទីរសាធារណៈការនិងដឹងជញ្ជូនខេត្ត ហើយគម្រោងនេះពិតជាបាន និងកំពុងសាងសង់លើគ្របគម្រោងក្រួសក្រហមរបស់

ឃុំអន្លង់វិលដែលបានសាងសង់កាលពីឆ្នាំ២០១៤ ប្រាកដមែន។ សំខាន់ជាងនេះទៀត គម្រោងកៅស៊ូរបស់មន្ទីរសាធារណៈការនិងដឹងជញ្ជូនខេត្តបានសាងសង់គ្របពីលើគម្រោងឃុំកម្ពស់ពី០,៦-១,០ម៉ែត្រ ព្រោះជាគម្រោងកែលម្អការធ្វើចរាចរ និងបម្រើជាទំនប់ទប់ទឹកជំនន់របស់ស្ទឹងដែលកើតមានឡើងស្ទើរៀងរាល់ឆ្នាំ។ ដូច្នេះ គម្រោងនេះពិតជាមានសារសំខាន់សម្រាប់ប្រជាពលរដ្ឋក្នុងឃុំអន្លង់វិល ពិសេសនៅភូមិក្បាលសរមាស។

ផ្អែកតាមមូលដ្ឋានដូចបានរៀបរាប់ខាងលើ យើងអាចសន្និដ្ឋានថា គម្រោងកៅស៊ូរបស់មន្ទីរសាធារណៈការនិងដឹកជញ្ជូនខេត្តពិតជាបាន និងកំពុងសាងសង់គ្របពីលើគម្រោងក្រួសក្រហមរបស់ឃុំអន្លង់វិល នៅភូមិក្បាលរមាស ហើយពិតជាមានសារសំខាន់ និងចាំបាច់សម្រាប់ប្រជាពលរដ្ឋរស់នៅតាមមាត់ស្ទឹងក្នុងការធ្វើដំណើរក៏ដូចជាការកាត់បន្ថយ និងការទប់ស្កាត់គ្រោះអាសន្នដែលបណ្តាលមកពីទឹកជំនន់។ អាស្រ័យហេតុនេះ លេខាធិការដ្ឋាន គ.ជ.អ.ប. ឯកភាពជាមួយអន្តរាគមន៍ និងការរៀបចំចាត់ចែងរបស់រដ្ឋបាលខេត្តពោធិ៍សាត់ មន្ទីរសាធារណៈការនិងដឹកជញ្ជូនខេត្ត និងក្រុមប្រឹក្សាឃុំអន្លង់វិលក្នុងការអនុវត្តគម្រោងនេះ។ ជាមួយគ្នានេះដែរ រដ្ឋបាលខេត្ត មន្ទីរសាធារណៈការនិងដឹកជញ្ជូនខេត្ត និងក្រុមប្រឹក្សាឃុំអន្លង់វិលត្រូវរៀបចំ និងរក្សាទុកឱ្យបានត្រឹមត្រូវនូវឯកសាររួមទាំងរូបភាពនានាពាក់ព័ន្ធនឹងគម្រោងក្រួសក្រហមឃុំអន្លង់វិល ឆ្នាំ២០១៤ និងគម្រោងកៅស៊ូរបស់មន្ទីរសាធារណៈការនិងដឹកជញ្ជូនខេត្ត ឆ្នាំ២០១៦ ដែលបាននិងកំពុងសាងសង់គ្របពីលើគម្រោងក្រួសក្រហមរបស់ឃុំអន្លង់វិល សម្រាប់ទុកជាឯកសារ និងជាមូលដ្ឋានសម្រាប់សវនកម្មនានា។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាសម្របសម្រួល និងរៀបចំចាត់ចែងអនុវត្តគម្រោងផ្លូវក្រាលកៅស៊ូនេះស្របតាមបទដ្ឋានបច្ចេកទេស ប្រកបដោយប្រសិទ្ធភាព និងទទួលបានគុណភាពខ្ពស់។

សូមឯកឧត្តមទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**